**មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស**

**CENTER FOR ALLIANCE OF LABOR AND HUMAN RIGHTS-CENTRAL**

ផ្ទះលេខ ៣៥៩ ផ្លូវលេខ ៦៩BT #359 Street 69BT Sangkat Boeung Tompun , Khan Meanchey, Phnom Penh

Tel: (855) 93 556 603 Email: info@central-cambodia.org Web: www.central-cambodia.org

*លេខៈ ៦៥ /២៣ /សង់ត្រាល់*

**គោរពជូន**

**ឯកឧត្តម ហេង សួរ**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**កម្មវត្ថុៈ** ស្នើសុំដាក់លទ្ធផលបូកសរុប និងអនុសាសន៍ពីសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី **«ការការពារសិទ្ធិ និងកិច្ចគាំពារសង្គមដល់ពលករចំណាកស្រុក តាមរយៈការជ្រើសរើសប្រកបដោយក្រមសីលធម៌»** ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម រដ្ឋមន្ត្រី** មេត្តាជ្រាបថា **មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស** ហៅកាត់ថា **សង់ត្រាល់** គឺជាអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើកកម្ពស់សិទ្ធិការងារ និងគាំពារដល់ក្រុមអ្នកធ្វើការងារតាមរយៈការផ្តល់សេវាជំនួយផ្នែកច្បាប់ និងមធ្យោបាយសមរម្យផ្សេងទៀតដើម្បីទទួលបាននូវអភិបាលកិច្ចល្អប្រកបដោយតម្លាភាព និងគណនេយ្យភាព។ កម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ របស់អង្គការសង់ត្រាល់ ក៏មានគោលដៅ និងសកម្មភាពរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការគាំពារ និងលើកកម្ពស់សិទ្ធិដល់ពលករចំណាកស្រុក និងពលករវិលត្រឡប់មកមាតុភូមិវិញផងដែរ។

នៅក្នុងអនុសាសន៍ចំនួន ១០ ចំណុច ដែល **ឯកឧត្តម រដ្ឋមន្ត្រី** បានផ្តល់ជាមូលដ្ឋាន និងជាធាតុចូលសម្រាប់កិច្ចពិភាក្សាក្នុងសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិ ស្តីអំពី **«ការរៀបចំកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាឆ្នាំ ២០២៤-២០២៨»** កាលពីពេលថ្មីៗកន្លងទៅនេះ ក៏មានរួមបញ្ចូល ចំនុចទី៥ ស្តីពី **«ពលករទេសន្តរប្រវេសន៍»** ដែលជាចំនុចអាទិភាពមួយ ក្នុងចំណោមចំនុចអាទិភាពជាច្រើនផ្សេងទៀត ដើម្បីជាប្រយោជន៍របស់ពលរដ្ឋកម្ពុជាទាំងមូល ស្របទៅនឹងគោលដៅរបស់រាជរដ្ឋាភិបាល។ ជាការពិតណាស់ ពលករចំណាកស្រុកក៏ជាក្រុមងាយរងគ្រោះផ្សេងទៀត ពួកគេបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមចំណែកជួយសង្គមជាតិ តាមរយៈការបង្កើនជំនាញ និងប្រាក់បញ្ញើត្រលប់មកស្រុកកំណើត។ ហេតុដូចនេះ ការការពារសិទ្ធិពលករចំណាកស្រុកត្រូវបានចាត់ទុកជាចំណុចអាទិភាព ដែលទាមទារអោយមានការចូលរួមចំណែកដោះស្រាយពីគ្រប់ភាគី និងដៃគូរពាក់ព័ន្ធនានា។

ក្នុងរយៈពេលអនុវត្តសកម្មភាពការងារកន្លងមក និងតាមរយៈការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិចំនួន៦លើក ក្នុងចន្លោះ ឆ្នាំ២០២១ ដល់ ២០២៣ ជាមួយភាគីពាក់ព័ន្ធ អញ្ជើញមកពីតំណាងក្រសួងស្ថាប័ន អង្គការជាតិ និងអន្តរជាតិ តំណាងពលករចំណាកស្រុក និងអ្នកប្រឹក្សាយោបល់សុវត្ថិភាពចំណាកស្រុក អង្គការសង់ត្រាល់ បានរកឃើញបញ្ហាប្រឈមដែលពលករចំណាកស្រុកកម្ពុជាជួបប្រទះ និងបានធ្វើការចងក្រងជាឯកសារ និងអនុសាសន៍មួយចំនួន គោរពជូន **ឯកឧត្តម រដ្ឋមន្ត្រី** ក្នុងគោលបំណងចូលរួមជួយដោះស្រាយបញ្ហាប្រឈម ការពារ

**មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស**

**CENTER FOR ALLIANCE OF LABOR AND HUMAN RIGHTS-CENTRAL**

ផ្ទះលេខ ៣៥៩ ផ្លូវលេខ ៦៩BT #359 Street 69BT Sangkat Boeung Tompun , Khan Meanchey, Phnom Penh

Tel: (855) 93 556 603 Email: info@central-cambodia.org Web: www.central-cambodia.org

សិទ្ធិ និងលើកកម្ពស់កិច្ចគាំពារសង្គមដល់ពលករចំណាកស្រុក នាឱកាសខួបលើកទី ២៤ នៃទិវាអ្នកចំណាកស្រុកអន្តរជាតិ ដែលប្រារព្ធឡើងនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ នេះ។

អាស្រ័យដូចបានរៀបរាប់ខាងលើ សូម **ឯកឧត្តម រដ្ឋមន្ត្រី** ជ្រាបជាព័ត៌មាន និងទទួលយកលទ្ធផលបូកសរុប និងអនុសាសន៍ដែលបានភ្ជាប់ជាមួយ ដោយក្តីអនុគ្រោះ។

អង្គការសេង់ត្រាល់ មានក្តីសោមនស្សរីករាយ ស្វាគមន៍ទទួលយកមតិត្រលប់ និងជួបជជែកពិភាក្សាបន្ថែម ក្នុងការឈ្វេងយល់ និងសហការឲ្យកាន់តែស៊ីជម្រៅ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការការពារសិទ្ធិ និងលើកកម្ពស់កិច្ចគាំពារសង្គមដល់ពលករចំណាកស្រុកកម្ពុជា។

សូម **ឯកឧត្តម រដ្ឋមន្ត្រី** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ។

ថ្ងៃចន្ទ ៦ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣

**ជ.នាយកប្រតិបត្តិ**

**ឃុន ថារ៉ូ**

***ចម្លងជូន៖***

- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ស្ថានទូតថៃប្រចាំកម្ពុជា
- ស្ថានទូតជប៉ុនប្រចាំកម្ពុជា
- ស្ថានទូតម៉ាឡេស៊ីប្រចាំកម្ពុជា

*(ដើម្បីជូនជ្រាបជាព័ត៌មាន)*

***ឯកសារភ្ជាប់៖***

ខ្លឹមសារលទ្ធផលបូកសរុប និងអនុសាសន៍ពីសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ

***ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖***

លោក **ឌី ថេហ្យា** ប្រធានកម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ ០៩៣ ៥៥ ៦៦ ៣១